# ប្រវត្តិជោគជ័យរបស់ក្រុមប្រឹក្សាស្ត្រី
# នៅក្នុងរដ្ឋាភិបាលប្រទេសឥណ្ឌា ( ប៉ាន់ឆាយ៉ាត )

## សេចក្តីផ្តើម

ប្រវត្តិជោគជ័យដែលខ្ញុំនឹងអត្ថាធិប្បាយប្រាប់នេះគឺមានប្រភពមកពីប្រទេសឥណ្ឌា។ ប្រវត្តិនេះនិយាយអំពីស្ត្រីចំនួន 330,000នាក់ ដែលបានចូលប្រឡូកក្នុងឆាកនយោបាយផ្លូវការ ហើយចំនួនស្ត្រីនេះនឹងកើនឡើងដល់ទៅជាង 1 លាននាក់ក្នុងពេលដ៏ឆាប់នេះ។

ប្រវត្តិនេះចាប់ផ្តើមដោយច្បាប់មួយដែលបានអនុម័តក្នុងឆ្នាំ 1983 នៅក្នុងរដ្ឋកាណាតាកាភាគខាងត្បូង។ ច្បាប់នេះរួមមានខចែងមួយដែលចែងថា អាសនៈចំនួន 25% នៅក្នុងក្រុមប្រឹក្សានឹងត្រូវរក្សាទុកឱ្យស្ត្រី។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះត្រូវបានប្រព្រឹត្តឡើងនៅឆ្នាំ 1987។ នៅថ្ងៃទី 1 ខែ ឧសភា ឆ្នាំ 1987 គណៈបក្សចាណាតាដាល់ (គណៈបក្សដែលបានឈ្នះឆ្នោត) បានអំពាវនាវឱ្យមានអនុសញ្ញាស្តីពីអ្នកតំណាងដែលបានជ្រើសរើសទាំង 56,000នាក់ ដែលក្នុងនោះចំនួន 25% គឺជាស្ត្រី។ វាជាទិដ្ឋភាពដ៏អស្ចារ្យមួយដែលមានស្ត្រីចំនួន 14,000នាក់ បានចូលរួមបង្ហាញនូវភាពរុងរឿងរបស់ស្ត្រី ហើយក្នុងនោះមានស្ត្រីចំនួន 80% បានចូលប្រឡូកផ្នែកនយោបាយជាលើកដំបូង ដោយមានសេចក្តីរំភើបនឹងជ័យជំនះរបស់ពួកគេ។

ក្នុងកំឡុងឆ្នាំ 1995 វត្តមានរបស់ស្ត្រីក្នុងជួររដ្ឋាភិបាលមូលដ្ឋានបានកើនឡើងច្រើន ដោយសារប្រទេសជាតិទាំងមូលបានធ្វើការផ្លាស់ប្តូរផ្នែករដ្ឋបាល/នយោបាយដើម្បីរក្សាទុកអាសនៈនៅក្នុងក្រុមប្រឹក្សាមូលដ្ឋានសំរាប់ស្ត្រី តាមរយៈវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី 73 និងទី 74។ **នៅប្រទេសឥណ្ឌា គេហៅប្រព័ន្ធនេះថា ជាប្រព័ន្ធស្ថាប័ន ប៉ាន់ឆាយ៉ាត់រ៉ាជ់(PRI)**។ ក្នុងនាមជាសមាជិករដ្ឋាភិបាលដែលត្រូវបានបោះឆ្នោតជ្រើសតាំង អំណាចស្ត្រីទាំងនេះរួមមានអំណាចធ្វើការសំរេចទៅលើទិសដៅ និងសន្ទុះនៃការអភិវឌ្ឍន៍នៅក្នុងតំបន់ និងអំណាចក្នុងការគ្រប់គ្រង និងពិនិត្យសង្កេតការអនុវត្តន៏ការសំរេចទាំងនោះ។

## ការបែងចែកប្រកបដោយវិជ្ជមាន

ការបែងចែកជាវិជ្ជមាននៃប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាត់រ៉ាជ់ បានបង្កើតឱ្យមានសន្ទុះផ្លាស់ប្តូរ។ ការចូលប្រឡូកក្នុងរដ្ឋាភិបាលមូលដ្ឋានរបស់ស្ត្រីក្នុងចំនួនដ៏ធំបែបនេះ ជាញឹកញាយមានចំនួនលើសពីតំរូវការ 33.3% ព្រមទាំងភាពជោគជ័យរបស់ពួកគេនៅក្នុងយុទ្ធនាការ ដូចជាភាពជោគជ័យលើបេក្ខជន បានធ្វើឱ្យមានការផ្លាស់ប្តូរលើផ្នត់គំនិតដែលគិតថា ស្ត្រីមិនចាប់អារម្មណ៍ផ្នែកនយោបាយ និងគ្មានពេលវេលាដើម្បីចូលរួមប្រជុំ ឬបំពេញកិច្ចការទាំងឡាយនៅក្នុងដំណើរការគណៈ-

បក្សនយោបាយនានា។ មានភស្តុតាងដែលបង្ហាញថា ស្ត្រីនឹងមិនបានចូលរួមក្នុងក្រុមប្រឹក្សាទាំងនេះក្នុងចំនួនដ៏ច្រើនបែប នេះទេ បើសិនជាមិនមែនដើម្បីហេតុផលអណត្តិរដ្ឋធម្មនុញ្ញទេនោះ។ វាជាសំពាធរបស់ច្បាប់ជាតិ រួមផ្សំជាមួយនឹងភាពចាំបាច់ផ្នែកនយោបាយក្នុងការឈ្នះឆ្នោត ដែលបានផ្លាស់ប្តូរទស្សនៈគណៈបក្សនយោបាយអំពីសមត្ថភាពរបស់ស្ត្រីនៅមានកិរិតសំរាប់ការិយាល័យសាធារណៈ។

ដូចនេះ ប្រវត្តិដែលខ្ញុំកំពុងអធិប្បាយនេះមានភាពស្មុគស្មាញ។ ការកំណត់នីតិបញ្ញត្តិដែលកំណត់លើការរក្សាអាសនៈទុកឱ្យស្ត្រី មិនមែនជាលទ្ធផលពីយុទ្ធនាការដែលមានសារៈសំខាន់ណាមួយដោយចលនារបស់ស្ត្រី ឬដោយភាពដឹកនាំយល់ដឹងអំពយេនឌ័រមិនធម្មតាណាមួយរបស់គណៈបក្សនយោបាយនោះទេ។ វាអាចមានសំពាធខ្លះៗពីខាងភាគីស្ត្រីរបស់គណៈបក្សចាណោតាដាល់ ហើយធ្លាប់មានប្រវត្តិអំពីការទាមទារតំណែងជាច្រើនសំរាប់ស្ត្រីនៅក្នុងការបែងចែកធម្មនុញ្ញភាពសំរាប់សភាមជ្ឈិម។ ប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាច់បានសង្កត់ធ្ងន់ទៅលើចំណុចប្រសព្វរវាងផលប្រយោជន៍យេន-ឌ័រ និងវណ្ណៈនៅក្នុងសង្គម ដោយសារការរក្សាអាសនៈទុកឱ្យខ្លួន បានធ្វើឱ្យស្ត្រីដែលក្រីក្រនិងទន់ខ្សោយមានលទ្ធភាពបង្ហាញពីមនសិកានយោបាយដ៏ជ្រាលជ្រៅរបស់ពួកគេ និងផលប្រយោជន៍ក្នុងការទទួលបានអំណាច។ សំរាប់ពួកគេវិញផ្នែកនយោបាយ និងការបោះឆ្នោតគឺជាមាគ៌ាដែលមានប្រយោជន៍ក្នុងការជៀសផុតពីភាពក្រីក្រ និងជាយន្តការផ្លាស់ប្តូរសង្គម។

## តើក្រុមប្រឹក្សាស្ត្រីទាំងនេះជានរណា?

- ស្ត្រីដែលត្រូវបានជ្រើសរើសភាគច្រើនជាអនក្ខរជន។ (ចំនួន 20% នៃបុរសដែលទទួលបានការអប់រំជំនាញបើប្រៀបធៀបទៅនឹងស្ត្រីមានចំនួន 5%)។
- ស្ត្រីភាគច្រើនបានប្រកាសខ្លួនថាជាមេគ្រួសារ។ ប៉ុន្តែ យើងដឹងថា ពាក្យនេះមានន័យទូលាយដោយរាប់បញ្ចូលទាំងការងារធ្ងន់ៗ ដូចជាសកម្មភាពរកប្រាក់ចំណូល។
- មានស្ត្រីចំនួនតែ 20% ប៉ុណ្ណោះ ដែលមានបទពិសោធន៍ខាងនយោបាយពីមុនមក បើប្រៀបធៀបទៅនឹងបុរសមានចំនួន 80%។

## ប្រវត្តិជោគជ័យក្រុមប្រឹក្សាស្ត្រីឥណ្ឌានៅប៉ាន់ឆាយ៉ាត

បទពិសោធន៍ពីប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាច់របស់ស្ត្រីបានកែប្រែពួកគេជាច្រើន។ កត្តាកែប្រែនេះរួមមានការផ្តល់អំណាច ភាពជឿជាក់ខ្លួនឯង ការយល់ដឹងពីនយោបាយ និងអំណះអំណាងលើអត្តសញ្ញាណ។ ស្ត្រីបានទទួលសតិអំពីការផ្តល់អំណាចដោយការអះអាងការគ្រប់គ្រងលើធនធាន មន្ត្រី និងភាគច្រើនបំផុតនោះគឺដោយការប្រជែងជាមួយបុរស (ចេន ឆ្នាំ 1980 អានវ៉ែសុី ឆ្នាំ 1993)។ បុរស និងទំលាប់របស់ពួកគេដែលស្ថិតនៅឆ្ងាយក្រៅរង្វង់ឥទ្ធិពលរបស់ស្ត្រីហាក់ដូចជាមានកង្វល់ចំបងអំពីស្ត្រីដែលត្រូវបោះឆ្នោតជ្រើសតាំង។

**សំដីដកស្រង់ពីសមាជិកក្រុមប្រឹក្សាស្ត្រីម្នាក់ (ឆ្នាំ 1995):**

> "ប្រសិនបើយើងនិយាយឥតសំចៃ ពួកគេ-បុរស១បាននិយាយអំពីយើងជាចំហ និងថាយើងគ្មានភាពអៀនខ្មាស់។ ប៉ុន្តែឥឡូវនេះ យើងមិនខ្វល់ទេពីព្រោះយើងដឹងថា យើងអាចចូលរួមជាមួយអ្នកដែលត្រូវស្តាប់យើង។ ថ្ងៃដែលយើងមានអង្គប្រជុំ **ក្រែម ប៉ាន់ឆាយ៉ាត** បុរស១និងអ្នកនៅផ្ទះបានសើចចំអកឱ្យយើង – នោះហើយគឺជាពេលដែលយើងយកសៀវភៅចេញ ហើយបង្ហាញដល់ពួកគេអំពីអ្វីដែលយើងបានដឹង"។

ការផ្តល់អំណាចរបស់ស្ត្រីក៏បានប្រជែងនឹងផ្នត់គំនិតបុរាណអំពីអំណាច និងឧត្តមភាពរបស់បុរស ព្រមទាំងភាពជឿជាក់លើខ្លួនឯងដែលទទួលបានតាមរយៈអង្គការក្នុងតំបន់ដែលបានធ្វើឱ្យពួកគេជៀសផុតពីទំនាក់ទំនងវិសមភាព។

> "ការអប់រំមិនមែនជាបញ្ហាធ្ងន់ធ្ងរទេនៅទីនេះ។ វាគឺជាភាពក្លាហាន និងការតាំងចិត្តដែលស្ត្រីមានគ្រប់គ្រាន់"។

ម្យ៉ាងវិញទៀត ការប្រឡូករបស់ស្ត្រីមួយចំនួននៅក្នុងប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាច់ បានជួយពួកគេក្នុងការអះអាងអំពីអត្តសញ្ញាណរបស់គេថាជាស្ត្រីដែលមានបទពិសោធន៍ជាក់លាក់ និងបានរួមចំណែក។ ស្ត្រីម្នាក់នៅអង្គប្រជុំប៉ាន់ឆាយ៉ាតក្នុងកាណាតាកាបានមានប្រសាសន៍ថា :

> "ពេលពួកយើងជួបគ្នា ពួកយើងធ្វើការរួមគ្នាក្នុងនាមជាស្ត្រីសំរាប់ក្រុមរបស់យើង។ ពួកយើងមិនចាប់អារម្មណ៍ច្រើនទេអំពីអត្តសញ្ញាណគណៈបក្សរបស់ពួកយើង"។

បុរសគិតថា អ្នកនយោបាយថ្មីទាំងនេះគឺជាស្ត្រីមិនមែនជាមិត្តរួមគណៈបក្សឡើយ។ នយោបាយគណៈបក្សដែលជាលក្ខខណ្ឌចាំបាច់សំរាប់ប្រជាធិបតេយ្យបុរាណ គឺមានលក្ខណៈប្រកួតប្រជែង ប៉ុន្តែស្ត្រីនាំមកនូវក្រមសីលធម៌មួយដែលមានលក្ខណៈសហការ ឬមិនប្រកួតប្រជែងក្នុងពេលដែលពួកគេបានធ្វើការរួមគ្នាក្នុងជួរគណៈបក្ស ហើយព្រមទាំងមានផលប្រយោជន៍ដូចគ្នា។ យេនឌ័រអាចជំនួសវណ្ណៈ និងជួរគណៈបក្ស។ ស្ត្រីបានបើកជំរុញលទ្ធភាពសំរាប់នយោបាយដើម្បីមិនត្រឹមតែមានមុខមាត់ថ្មីប៉ុណ្ណោះទេ ថែមទាំងមានគុណភាពថ្មីផងដែរ។

វិធីមួយចំនួនដែលស្ត្រីកំពុងតែធ្វើការផ្លាស់ប្តូរអភិបាលកិច្ចតាមរយៈប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាច់ គឺមានស្តែងចេញនៅក្នុងបញ្ហាទាំងឡាយដែលពួកគេជ្រើសរើសក្នុងការដោះស្រាយ: ទឹក ការប្រើប្រាស់ជាតិស្រវឹង ការអប់រំ សុខភាព និងអំពើហឹង្សាក្នុងគ្រួសារ។ ឧទាហរណ៍ ស្ត្រីចំនួន 40 ក្រុមនៅក្នុងតំបន់សុនបាដ្រា (**អ៊ុតតាប្រាដែស**) បានអនុវត្តយ៉ាត្រាជាប្រព័ន្ធ ឬក្បួនគ្របដណ្តប់ទៅលើភូមិចំនួន 10 សំរាប់ក្បួនទីមួយ១ ឬចំនួន 4000ភូមិ សំរាប់ក្បួនទាំងអស់ ដើម្បីពន្យល់ពីលក្ខណៈសំខាន់នៃវិសោធនកម្មលើកទី 73 និងទីកន្លែងចន្លោះផ្តល់សំរាប់ស្ត្រី។ នៅក្នុងការពិភាក្សាក្នុងកំឡុងពេលយ៉ាត្រានេះ ស្ត្រីបានបង្ហាញពីអាទិភាពយ៉ាងច្បាស់លាស់។ សំរាប់ស្ត្រីចំនួនជិត 90% មានអាទិភាពខ្ពស់បំផុតគឺទឹក។ ពួកគេសំដែងពីតំរូវការទឹកស្អាតសំរាប់ស្រែចំការ សំរាប់គោក្របី និងសំរាប់គ្រួសាររបស់ពួកគេ។ ពួកគេនិយាយថា មិនអាចទ្រាំទ្របាន

នឹងការរស់នៅ និងការដាំដំណាំបានទេ បើគ្មានការអភិវឌ្ឍន៍ធនធានទឹកតំបន់។ ទោះបីពួកគេតាំងចិត្តរារាំងការហូរទឹកចេញពីតំបន់របស់ពួកគេក៏ដោយ ក៏ពួកគេព្រមគ្នាសំរេចថា នឹងបង្ការការហូរចូលជាតិស្រវឹងទៅក្នុងតំបន់របស់ពួកគេ។

មជ្ឈមណ្ឌលសំរាប់ឯកសារ និងការស្រាវជ្រាវរបស់ស្ត្រីនៅ**ពូន**បានរកឃើញថា នៅ**បីតតាហ្គន់**មានសមាជិក 2 នាក់ក្នុងចំនោម 9 នាក់ប៉ុណ្ណោះ ដែលអាចចុះហត្ថលេខាឈ្មោះរបស់ពួកគេបាន។ ប៉ុន្តែ ក្នុងភូមិនេះដែលមានចំនួនអ្នកភូមិ 16,000នាក់ ក្រុមប្រឹក្សាស្ត្រីបាន "ដឹងពីរឿងរាវនានាពីគ្រូបង្រៀនតាមសាលា និងហ្វ្រេមសេរ៉ាក់ (កម្មករតាម ជនបទ)។ ពួកគេបានឈប់លេងល្បែង ហើយបានផឹកស្រាយ៉ាងងប់ងល់"។ ពួកគេបានអនុវត្តគោលការណ៍នយោបាយ "**បិទច្រកទ្វារប្តីស្រវឹងទាំងអស់**"។

"យើងមិនទ្រាំនៅទេ។ នៅពេលយើងទទួលបានឋានៈ អំណាច យើងនឹងប្រយុទ្ធ។ យើងដឹងថា វាមិនងាយស្រួលទេ ពីព្រោះសង្គ្រាមនេះនឹងត្រូវផ្ទុះឡើងនៅគ្រប់ផ្ទះ។ ប៉ុន្តែដោយសារប៉ាន់ឆាយ៉ាតតំរូវឱ្យមានចំនួនស្ត្រីអប្បបរមានោះ យើងនឹងប្រើភាពរឹងមាំនេះដើម្បីប្រើប្រាស់ចលនាស្ត្រីឱ្យបានទូលំទូលាយ ហើយបំបាត់ជាតិស្រវឹងចេញជាអាទិភាព"។

ស្ត្រីកំពុងតែខិតជិតទៅរកការគាំទ្ររបស់ពួកគេ។ "ស្ត្រីក្រីក្រត្រូវតែឈានឱ្យដល់ភាពសំរបសំរួលទាំងនេះ ដែលត្រូវចំណាយពេលវេលាដ៏មានតំលៃយ៉ាងយូរ។ ម្យ៉ាងទៀត នៅពេលមានការវាយប្រហារ ការចាប់រំលោភ ការដុត ការប្រមាញ់ ឬអំពើហឹង្សាផ្សេងទៀតប្រឆាំងនឹងស្ត្រី ការស្វែងរកដំណោះស្រាយពីក្រុមប្រឹក្សាដែលស្ថិតនៅឆ្ងាយ ប្រហែលជាមិនអាចទៅរួចទេ។ ប៉ុន្តែបើសិនជាក្រុមប្រឹក្សាទាំងនេះ និងសមាជិកមានឱកាសរកដំណោះស្រាយ និងសកម្មភាពដ៏មានប្រសិទ្ធភាព គឺមានទំហំធំជាង"។

## <u>ឧបសគ្គរួម</u>

មានឧបសគ្គជាច្រើនក្នុងការបំពេញឱ្យបានសំរេចនូវសក្តានុពលការកែប្រែប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាជ់។ មានភាពសង្ស័យជាច្រើនអំពីវិមជ្ឈការ។ ហើយនៅតែមានការប្រឆាំងទៅនឹងអំណាចផ្ទេរពិតប្រាកដនិងមូលនិធិពីមជ្ឈដ្ឋានមជ្ឈិមទៅបរិមណ្ឌល។ ស្ត្រីនៅតែប្រឈមមុខនឹងភាពងងឹតងងល់ចំពោះការចូលរួមនៅក្នុងនយោបាយរបស់ពួកគេ ឧទាហរណ៍ ការអប់រំមិនគ្រប់គ្រាន់ បន្ទុកលើតួនាទីបន្តពូជ និងផលិតកម្ម កង្វះភាពជឿជាក់ខ្លួនឯង និងការប្រឆាំង និងទស្សនៈសាសនា និងវប្បធម៌ដែលកប់ជ្រៅ។

នៅមានឧបសគ្គខាងផ្នែករដ្ឋបាលដែលត្រូវពុះពារផងដែរ។ ក្របខ័ណ្ឌរដ្ឋបាលបច្ចុប្បន្នមានទំរង់ជាការផ្តល់មូលនិធិដោយផ្នែក ដែលគ្រប់គ្រងរដ្ឋបាលតាមនាយកដ្ឋានដែលមានទំនាស់នឹងកម្មវិធីតំបន់ដឹកនាំដោយស្ត្រី ដែលកើតចេញពីប្រព័ន្ធ ស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាជ់។

វិមជ្ឈការអាចធ្វើឱ្យកង្វះធនធានក្នុងតំបន់កាន់តែធ្ងន់ធ្ងរ និងបន្តឱ្យមានគំលាតរវាងតំបន់។ រដ្ឋាភិបាលកណ្តាលបានអនុវត្តមិនត្រឹមត្រូវចំពោះការបំបាត់លក្ខខណ្ឌសុវត្ថិភាពសង្គម។ ហើយវាក៏ត្រូវបានគេអនុត្តមិនត្រឹមត្រូវខាងផ្នែកនយោបាយផងដែរដោយជនផ្តាច់ការ ឬរបបកាន់អំណាចម្នាក់ឯងក្នុងការគ្រប់គ្រងចាប់ពីមជ្ឈិមតាមរយៈយន្តការធ្វើវិមជ្ឈការ។

## ការគាំទ្រស្ត្រីចំពោះស្ត្រី

ក្រុមប្រឹក្សាស្ត្រីនៅប៉ាន់ឆាយ៉ាតបានស្នើរឱ្យមានការគាំទ្រជាក់លាក់ ដែលហួសពីការបណ្តុះបណ្តាលបច្ចេកទេស។ យើងត្រូវការការគាំទ្រដើម្បីបង្កើតសាមគ្គីភាពក្នុងចំណោមស្ត្រីតាមរយៈពង្រឹងសម្ព័ន្ធភាពរវាងអង្គការស្ត្រី និងស្ថាប័នដែលបានបោះឆ្នោតជ្រើសរើស។ យើងត្រូវការពតិមានអំពីអង្គការស្តារ និងអភិវឌ្ឍន៍មួយចំនួន ដែលអាចជួយលើកស្ទួយជីវភាពរបស់ស្ត្រីដូចជាអ្នកផ្តល់សេវាខាងសុខភាព ស្ថាប័នឥណទាន ។ល។ អង្គការក្រៅរដ្ឋាភិបាលសំរាប់ស្ត្រីភាគច្រើនកំពុងតែផ្តល់ការគាំទ្របែបនេះរួចហើយដល់តំណាងស្ត្រី។

ទោះបីជាយ៉ាងណាក៏ដោយ នៅមានគំលាតចំបងនៅក្នុងការគាំទ្រស្ត្រីចំពោះស្ត្រីនេះ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពីចលនាសំរាប់ស្ត្រីឥណ្ឌា និងក្រុមស្ត្រីនៅក្នុងតំបន់។ ផ្នែកជាច្រើននៃចលនានេះ ដើមដំបូងមានការសង្ស័យអំពីតំលៃពិតនៃ "ប៉ាន់ឆាយ៉ាត និងប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាច់" នេះ ប៉ុន្តែពេលដែលពួកគេកាន់តែស្និទ្ធស្នាលជាមួយនឹងស្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសតាំង ពួកគេរំភើបដោយភាពក្លៀវក្លា និងសេចក្តីសាទររបស់ស្ត្រី ហើយឥឡូវនេះកំពុងតែផ្តល់ការគាំទ្រទាំងផ្នែកសីលធម៌ និងសម្ភារៈ។ ដំណើរការនេះមានសារសំខាន់ណាស់ ហើយត្រូវតែបន្ត និងជំរុញបន្ថែម។

## ឧទាហរណ៍នៃការគាំទ្រចលនារបស់ស្ត្រី

- សំរបសំរួលការប្រជុំរបស់ពួកគេតាមបណ្តាស្រុក
- ធានាថា ស្ត្រីគ្មានភាពទន់ខ្សោយក្នុងរចនាសម្ព័ន្ធគណៈកម្មាធិការចំណាយ និងចំណូលដែលត្រូវបង្កើតឡើងដើម្បីគ្រប់គ្រងការអភិវឌ្ឍន៍នៅក្នុងអង្គការទាំងនេះទេ
- ធានាទៅលើការផ្ទេរអំណាចលើការរៀបចំគំរោង និងការត្រួតពិនិត្យអំណាចពីរដ្ឋាភិបាលកណ្តាលទៅស្ថាប័នដែលបានជ្រើសតាំង
- ពង្រឹងអត្តសញ្ញាណ និងការយល់ដឹងអំពីការតំលើងឋានៈស្ត្រីដល់តំណាងស្ត្រី ឧទាហរណ៍ តាមរយៈការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ។
- ដឹកនាំស្ត្រីឱ្យចូលក្នុងរចនាសម្ព័ន្ធនយោបាយ និងគាំទ្រសម្ព័ន្ធភាពខាងមុខនិងខាងក្រោយនៃវត្តមានស្ត្រីនៅក្នុងផ្នែកនយោបាយដោយផ្សារភ្ជាប់គ្រួសារ និងអាទិភាពគ្រួសារជាមួយនឹងដំណើរការធ្វើផែនការម៉ាក្រូ។

## សារសំខាន់ចុងក្រោយ

ការស្វែងរកសមភាពមិនអាចនឹងឈានដល់ទេ បើគ្មានការតំណាងដ៏ទូលំទូលាយពីក្រុមទាំងអស់ ជាពិសេសពីអ្នកដែលបច្ចុប្បន្ននេះកំពុងតែមិនចង់បានអំណាចព្រមទាំងវត្តមាននៃគ្រប់ទស្សនៈទាំងអស់នៅក្នុងដំណើការធ្វើការសំរេចចិត្ត។

ប្រវត្តិរបស់ឥណ្ឌារំលឹកយើងអំពីរឿងពិតមួយ អំណាចមិនមែនជាអ្វីដែលប្រជាជនបោះបង់ចោលនោះទេ។ វាត្រូវតែមានការចរចារ។ មេរៀនរបស់ស្ថាប័នប៉ាន់ឆាយ៉ាត់រ៉ាច់មានភាពច្បាស់លាស់ : បើសិនជាគតិបណ្ឌិតអង្គការប្រជាជនសាមញ្ញ ជាពិសេសសេចក្តីក្លាហាន និងភាពច្បាស់លាស់របស់ស្ត្រីត្រូវប្រែក្លាយជាគោលការណ៏នយោបាយនៅរដ្ឋាភិបាលមូលដ្ឋាន យើងចាំបាច់ត្រូវរួបរួម និងមានតំរូវការច្បាស់លាស់សំរាប់សំលេងគាំទ្ររបស់ពួកយើង ដើម្បីទទួលបាន អំណាច។

## ប្រភពឯកសារ


Jain, Devaki .1996.Panchayt Raj: Women Changing governance.

Jain, L.C. 1994. "Panchayats: Women Will Win", in Kurukshetra Narayanan,IDS Bulltin, No 121,Brighton.

Revathi.1993. "Women in Panchayati Raj: Experiences from Karnataka", in Search Newsletter, Bangalore.


**កំណត់សំគាល់ :** សំដីដកស្រង់ទាំងអស់ក្នុងឯកសារនេះត្រូវបានស្រង់ចេញពីសារពត៌មានស្តីពី "ស្ត្រីផ្លាស់ប្តូរអភិបាលកិច្ចល្អ"។

ការបង្ហាញជូនខាងលើនេះ គឺជាសេចក្តីសង្ខេបនៃសារពត៌មានដែលសរសេរដោយលោក **ចេន ដេវ៉ាគី** ដែលជាអ្នកនិពន្ធដ៏ល្បីឈ្មោះ និងជាសកម្មជនគាំទ្រស្ត្រីនៅប្រទេសឥណ្ឌា។